សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៨២៨
ចុះថ្ងៃទី ១៨.០៣.២០១២
សាលក្រម
លេខ ៨៥ "យ "
ចុះថ្ងៃទី ២២.១០.២០១៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៣ ដែលមានសមាសភាព ជំនុំជម្រះដូចតទៅ ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ជាក្រឡាបញ្ជីអមសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ ៨២៨ ចុះថ្ងៃទី ១៨.០៣.២០១២ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ មិនលំនៅសព្វថ្ងៃផ្ទះលេខ៤១ ផ្លូវលេខ១៣៦ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] ( ) ម្តាយឈ្មោះ[redacted] ( ) ប្រពន្ធឈ្មោះ[redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៧៧៣ តក្រ ចុះថ្ងៃទី ១៩.០៥.២០១៣

២.ឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨០០៨៣១៨៣ មានទីលំនៅផ្ទះលេខ ៩២ ផ្លូវលេខ ២១៤ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

មេធាវី [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

ដើមបណ្តឹងរដ្ឋប្បវេណី

ឈ្មោះ [redacted] ភេទប្រុស កើតនៅឆ្នាំ ១៩៨១ សញ្ជាតិខ្មែរ អាស័យដ្ឋានផ្ទះលេខ ៤៥៤ ផ្លូវម៉ៅសេទុង សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

មេធាវី [redacted] មេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងរដ្ឋប្បវេណី (វត្តមាន)

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៣០ អ.យ.ឆ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៣៣៨ ដជរ ចុះថ្ងៃទី ៣០.០៧.១៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។



Scanned by CamScanner

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា ៖ ដោយសារក្រុមហ៊ុនមានវិបត្តិហិរញ្ញវត្ថុ ហើយមានខ្ញុំជាតំណាងក្រុមហ៊ុន ក៏បានធ្វើកិច្ចសន្យាបញ្ជាក់នៅជំពាក់ប្រាក់ដែលនៅសល់ចំនួន ២ម៉ឺនដុល្លាជាង ។ ហើយដោយសារការរងចាំគាត់មានរយៈពេលយូរ–ក៏មានការប្តឹងផ្តល់លើរូបខ្ញុំ ។ ហើយក៏មានការទូទាត់ប្រាក់សែកចំនួន ២ម៉ឺនដុល្លា និង ៥០០០ដុល្លា ជាថ្លៃពន្យាពេល ។ ប្រសិនបើខ្ញុំប្តឹងផ្តល់នៅខេត្តក្រចេះបានហើយ មិនព្រមសងទេ គឺខ្ញុំទទួលខុសត្រូវ ។ សែកដែលបានចេញគឺធានាប្រាក់ចំនួន ១០ម៉ឺនដុល្លា និងប្រគល់ប្រាក់មកក្រុមហ៊ុនខ្ញុំវិញ ។ ខ្ញុំជាអ្នកធានាចេញសែកឲ្យក្រុមហ៊ុន [redacted]។ សែកនេះធានាការទូទាត់ដោយមានស៊ីញ៉េខ្ញុំបាទជាអ្នកតំណាង ហើយមានការបញ្ជាពីក្រុមហ៊ុន ។ លុយ ១០ម៉ឺនដុល្លា ខ្ញុំ និងឈ្មោ[redacted] ជាអ្នកបញ្ជាពីលោក [redacted] ឲ្យខ្ញុំចេញ ។ ខ្ញុំពិតជាបានចេញមូល្បទានប័ត្រមែន ចំនួនទឹកប្រាក់ ២៣០០០ដុល្លា ហើយ ៥០០០ដុល្លាទៀត ជាថ្លៃយឺតយ៉ាវ ហើយខ្ញុំជាអ្នកប្រគល់ឲ្យលោ[redacted] ពេលដែលខ្ញុំចេញសែក មានឈ្មោះ ខ្ញុំ និងឈ្មោះ[redacted] មានគណនីនៅធនាគារ ។មានឈ្មោះ[redacted] និង[redacted]ជាអ្នកបោះត្រា ។ មានខ្ញុំ និង[redacted] ជាម្ចាស់ភាគហ៊ុន ចំពោះលក្ខន្តិកៈ ខ្ញុំបានប្រ[redacted] ជាម្ចាស់ក្រុមហ៊ុន Rock Steel មានតែឈ្មោះ [redacted]ជាអ្នកចុះកិច្ចសន្យាតំណាងក្រុមហ៊ុន ។ គណនីលេខនេះ គល់ជូនហើយ គឺពេលនោះមានតែខ្ញុំ និង[redacted] ។ ខ្ញុំទទួលស្គាល់លិខិតជំពាក់ប្រាក់ចំនួន ២៧០០០ដុល្លាអាមេរិក ។ គឺមានតែឈ្មោះខ្ញុំ និង[redacted]បានឈប់ទើបមិនមាន សែកនេះខ្ញុំ ប្រគល់ឲ្យគាត់តាំងពីចុះកិច្ចសន្យាជាមួយគ្នា ដោយសារឈ្មោះ[redacted]មិនមានការពាក់ព័ន្ធទៀត ព្រោះគាត់បានលា ឈ្មោះគាត់ពាក់ព័ន្ធ ។ ខ្ញុំបិទគណនីដោយសារឈ្មោះ[redacted]ថាគណនីបានបិទ ។ លែងតំណែងពីការងារ ។ ខ្ញុំបានប្រាប់[redacted]

-ក្រឡាបញ្ជីបានអានកំណត់ហេតុសួរចម្លើយជនជាប់ចោទនៅអយ្យការ និងនៅចៅក្រមស៊ើបសួរ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]បានឆ្លើយថា ខ្ញុំឈ្មោះ[redacted]ជាម្ចាស់ក្រុមហ៊ុន L.M

សែកត្រូវបានបិទហើយហេតុអី ហើយគាត់មិនបានបញ្ជាក់ប្រាប់ខ្ញុំទេថា គណនីនោះត្រូវបានបិទទេ ។ ហើយ បញ្ជាក់ក្នុងកិច្ចសន្យាជំពាក់ប្រាក់ចំនួន ២៧៣៨០ ដុល្លា ។ ការពិតវាមិនពិតទេ ៥០០០ដុល្លា ទូទាត់តាមការដាក់ ស្តែងមិនមែនការពន្យាពេលទេ ។ មិនមានពាក់ព័ន្ធនឹងតុលាការនៅខេត្តក្រចេះទេ ។ គឺបាន តំកល់ហួតតែមិនមាន ចុះថ្ងៃខែឆ្នាំទេ ។ ធនាគារសំខាន់ផ្តោត លើការស៊ីញ៉េការតំកល់១០ម៉ឺនដុល្លា ដើម្បីធានាការខូចខាត ។ គាត់ដឹងថា គណនីបិទហើយតែគាត់នៅតែបំពាន ។ ពេលស៊ីញ៉េគឺ [redacted]ជាអ្នកស៊ីញ៉េ ជាមួយគ្នា ។ សំណូមពរ សុំឲ្យជនជាប់ចោទសងប្រាក់ចំនួន ២៧៣៨០ ដុល្លាអាមេរិក និងទាមទារសំណងជម្ងឺចិត្តចំនួន ១០០០០ដុល្លា អាមេរិក ការប្រាក់ ២ភាគរយក្នុងមួយខែ រហូតសងគ្រប់ និងសុំផ្តន្ទាទោសអតិបរមា ។

-ក្រឡាបញ្ជីអានលិខិតបង្វិលមូលប្បទានប័ត្រក្រឡប់ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់ថា យោងតាមការសួរដេញដោល អង្គហេតុថ្ងៃទី ០១.០៨.២០១១ លោក[redacted]និងលោក[redacted]បានចុះកិច្ចសន្យាទិញប្រេងជាមួយ កូនក្តីខ្ញុំ ហើយបានផ្គត់ផ្គង់ប្រេងអោយលោក[redacted] ហួត ។ ហើយបានឯកភាពលើបំណុល ២៣៣៨០ ដុល្លា ។ ហើយសន្យាសងនៅថ្ងៃ ២៩ ហើយភាគីទាំងពីរបានឯកភាពចេញមូលប្បទានប័ត្រឲ្យកូនក្តីខ្ញុំ ហើយជន ជាប់ចោទទាំងពីរនាក់បានឆបោកកូនក្តីខ្ញុំ ដោយចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ ហើយគណនីរបស់គាត់បាន បិទ ប៉ុន្តែគាត់មិនបានប្រាប់កូនក្តីខ្ញុំទេ នៅតែអះអាងថា ក្នុងសែកអាចបើកប្រាក់បាន ។ ដូច្នេះមានភស្តុតាង និង ដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]និងឈ្មោះ [redacted]បែម ចេញមូលប្បទានប័ត្រ គ្មានសាច់ប្រាក់។ តាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍រាចរឿញបាន ។ ទី១ សុំផ្តន្ទាទោសបានធ្ងន់បំផុត ទី២



Scanned by CamScanner

សុំឲ្យសងប្រាក់ ២៧៣៨០ និងការប្រាក់ ២ភាគរយ និងសំណងជម្ងឺចិត្ត ១០០០០ដុល្លាអាមេរិក និងចេញដីកា 55/3

ចាប់ខ្លួន ឈ្មោ[redacted]

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ

ឆ្លងតាមសវនាការរួចមក យល់ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើចេញសែកអត់លុយឲ្យទៅដើមបណ្តឹងប្រាកដមែន ដូច្នេះតំណាងអយ្យការសម្រេចតំកល់ការចោទប្រកាន់ និងដីកាសន្និដ្ឋានស្ពាររទុកជាបានការដដែល និងសុំឲ្យផ្តន្ទាទោសតាមច្បាប់ ។

ជនជាប់ចោទសំណូមពរ បដិសេធការចោទប្រកាន់របស់ដើមបណ្តឹង និងសុំដោះលែងខ្ញុំបាទឲ្យមានសេរីភាពវិញផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានលិខិតមូលប្បទានប័ត្រក្រឡប់

-ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារ

-ក្រោយពីបានស្តាប់តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង

**សំអាងហេតុ**

១-កាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១១ ស្ថិតនៅចំណុចរាជធានីភ្នំពេញ ពិតជាមានករណី ចេញមូលប្បទានប័ត្រមួយសន្លឹកដោយគ្មានសាច់ប្រាក់ ក្នុងគណនី ប្រាកដមែន ដោយមានមូលប្បទានប័ត្រលេខ ០២៩៧៧៥ [redacted] ប្រាកដមែន ។ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោ[redacted]និងឈ្មោ[redacted]

២-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយនៅពេលសវនាការថា ខ្លួន និងឈ្មោះ [redacted] ម្សៅជាក់ជានាប់ណុលទុទាត់ថ្លៃប្រេងចំនួន ២៧៣៨០ដុល្លា បានស៊ីញ៉េសែកមួយ សន្លឹកឲ្យទៅឈ្មោះ[redacted]ប្រទេសក្នុង ហើយគណនីនេះត្រូវបានខ្លួនបិទ ដោយសារឈ្មោះ[redacted] ដោយមានការបញ្ជាពីឈ្មោះ[redacted]ជាម្ចាស់ក្រុមហ៊ុនប្រេង L.M ថា [redacted]បានលាឈប់ពីការងារ ។ ហើយខ្លួនបានប្រាប់ ឈ្មោះ[redacted]បានឆ្លើយថា សែកត្រូវបានបិទគណនីនេះបានបិទហើយ ។ ចំពោះចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ហើយពេលស៊ីញ៉េសែកនោះ ឈ្មោះ[redacted] ហើយ ហេតុអីត្រូវទទួលយក ហើយក៏មិនបានប្រាប់ខ្លួនថា គណនីបិទដែរ ក្រឡប់របស់ [redacted]និងឈ្មោះ[redacted]ជាអ្នកស៊ីញ៉េរួមគ្នា ។ម្យ៉ាងទៀតលិខិតបង្វិលមូលប្បទានប័ត្រ ធនាគារបានបញ្ជាក់ថា ម្ចាស់គណនីបានសុំបិទគណនី ។ ដូច្នេះចម្លើយរបស់ជនជាប់ចោទ ឈ្មោះ[redacted] ជាចម្លើយដោះសារមិនមានភស្តុតាងណាមួយអាចឲ្យជឿជាក់បាន ។

៣អំពើរបស់ជនជាប់ចោទឈ្មោះ[redacted]និងឈ្មោ[redacted]ពិតជាបានចេញមូលប្បទានប័ត្រទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]ដោយគ្មានសាច់ប្រាក់ក្នុងគណនី ប្រាកដមែន ដោយឈ្មោះ[redacted] ហើយពេលក្រុមហ៊ុនបានទទួល [redacted] បានចេញមូលប្បទានប័ត្របញ្ជាទិញប្រេងពីក្រុមហ៊ុនប្រេង L.M ហើយពេលក្រុមហ៊ុនបានទទួលបញ្ជាទិញដោយការប្រគល់មូលប្បទានប័ត្រនោះ ខាងក្រុមហ៊ុនបានបញ្ចេញប្រេងទៅតាមការបញ្ជាទិញរបស់ឈ្មោះ [redacted] ប៉ុន្តែដល់ពេលទៅបើកប្រាក់ក្នុងមូលប្បទានប័ត្រ ខាងធនាគារបង្វិលមូលប្បទានប័ត្រមកវិញ ថាគ្មានលុយប្រាក់នោះទេដោយសារម្ចាស់គណនីសុំបិទគណនី ។ ដូច្នេះអំពើរបស់ជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ [redacted] គឺជាការមិនបំពេញ កាតព្វកិច្ចចំពោះឧបករណ៍អាចផ្ទេរជួញដូរបានដែលបានធ្វើឲ្យខូច



Scanned by CamScanner

ប្រយោជន៍ដើមបណ្តឹង ។ ដូច្នេះអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បាន
រំលោភទៅលើមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៤.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានប្តឹងទាមទារសំណងចំនួន ២៧៣៤០ដុល្លា(ពីរម៉ឺនប្រាំពីរពាន់បីរយសែសិបដុល្លាអាមេរិក) និងជម្ងឺចិត្តចំនួន ១០០០០ដុល្លា(មួយម៉ឺនដុល្លាអាមេរិក) ការប្រាក់ ២ភាគរយក្នុង ១ខែ រហូតសងគ្រប់ និងសុំផ្តន្ទាទោសអតិបរមា តប្បីតុលាការពិចារណាដល់បញ្ហានេះ។

៥.មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់ថា យោងតាមការសួរដេញដោយអង្គហេតុថ្ងៃទី ០១.០៨.២០១១ លោក [redacted] និងលោក [redacted] បានចុះកិច្ចសន្យាទិញប្រេងជាមួយកូនក្តីខ្ញុំ ហើយបានផ្គត់ផ្គង់ប្រេងអោយលោក [redacted] រហូត ។ ហើយបានឯកភាពលើបំណុល ២៣៣៤០ ដុល្លា ។ ហើយសន្យាសងនៅថ្ងៃ ២៩ ហើយភាគីទាំងពីរបានឯកភាពចេញមូលប្បទានប័ត្រឲ្យកូនក្តីខ្ញុំ ហើយជនជាប់ចោទទាំងពីរនាក់បានឆបោកកូនក្តីខ្ញុំ ដោយចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ ហើយគណនីរបស់គាត់បានបិទ ប៉ុន្តែគាត់មិនបានប្រាប់កូនក្តីខ្ញុំទេ នៅតែអះអាងថា ក្នុងសែកអាចបើកប្រាក់បាន ។ ដូច្នេះមានភស្តុតាង និងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បទ ចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់។ តាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញបាន ។ ទី១ សុំផ្តន្ទាទោសបានធ្ងន់បំផុត ទី២ សុំឲ្យសងប្រាក់ ២៧៣៤០ និងការប្រាក់ ២ភាគរយ និងសំណងជម្ងឺចិត្ត ១០០០០ដុល្លាអាមេរិក និងចេញដីកាចាប់ខ្លួន ឈ្មោះ [redacted] តប្បីតុលាការពិចារណាតាមច្បាប់ ។

៦-លោកតំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើចេញសែកអត់លុយឲ្យទៅដើមបណ្តឹងប្រាកដមែន ដូច្នេះតំណាងអយ្យការសម្រេចតំកល់ការចោទប្រកាន់ និងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឲ្យផ្តន្ទាទោសតាមច្បាប់ ។ តប្បីតុលាការពិចារណាតាមផ្លូវច្បាប់ ។

៧-សំដីចុងក្រោយរបស់ជនជាប់ចោទបានសុំបដិសេធការចោទប្រកាន់របស់ដើមបណ្តឹង និងសុំដោះលែងខ្លួនឲ្យមានសេរីភាពវិញផង តប្បីតុលាការពិចារណាតាមច្បាប់ ។

[redacted] និងឈ្មោះ [redacted] ពីបទ
៨-មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted]
មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែសីហា
ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

**<u>ហេតុដូច្នេះសម្រេច</u>**

១/ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ [redacted] ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ

ខ.ឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ

ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាច
ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០១ឆ្នាំ ០៦ខែ
ជួញដូរបាន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១១ តាមមាត្រា ២៣១ នៃច្បាប់ស្តីពី
ឧបករណ៍អាចជួញបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

[redacted] និងជនជាប់ចោទឈ្មោះ [redacted] រួមគ្នាសង
២/បង្គាប់ឲ្យជនជាប់ចោទឈ្មោះ
សំណងការខូចខាតចំនួន ២៧៣៤០ដុល្លា(ពីរម៉ឺន ប្រាំពីរពាន់បីរយដុល្លាអាមេរិក) និងសំណងជម្ងឺចិត្តចំនួន
១០០០ដុល្លា (មួយពាន់ដុល្លាអាមេរិក) ទៅឲ្យដើមបណ្តឹង រដ្ឋប្បវេណីឈ្មោះ [redacted] ពេលសាលក្រមចូលស្ថាពរ ។ ការទាមទារលើសពីនេះច្រានចោល ។



Scanned by CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ** |
| --- | --- |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

**បានឃើញ**
**ចៅក្រម**
[redacted]

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-
ភ្នំពេញ ថ្ងៃទី 13 ខែធ្នូ ឆ្នាំ២០១៣
**ក្រឡាបញ្ជី**
[redacted]



Scanned by CamScanner